# ជំពូកទី ៥

## ៥. ជំរើស

មានជំរើសដែលអាចធ្វើបានចំនួន២ ដែលបានយកមកប្រៀបធៀបសំរាប់គំរោងដែលបានស្នើសុំ ដោយរាប់បញ្ចូលនូវ ទីកន្លែង បច្ចេកវិជ្ជា និង ជំរើសនៃប្រតិបត្តិការ ។ ជំរើសនោះត្រូវបានប្រៀបធៀបក្នុងន័យសក្តានុពលនៃហេតុប៉ះពាល់បរិស្ថានរបស់វា ដើមទុន និង តំលៃទទួលត្រឡប់វិញ ភាពសមស្របទៅនឹងស្ថានភាពក្នុងតំបន់ និង តំរូវការ ស្ថាប័ន ការបណ្តុះបណ្តាល និង ការពិនិត្យតាមដាន ។ តំលៃចំណាយបរិស្ថាន និងផលចំណេញ សំរាប់ជំរើសនិមួយៗត្រូវបានកំរិតចំនួនទៅតាមលទ្ធភាពដែលអាចធ្វើបាន។ គុណតំលៃសេដ្ឋកិច្ចត្រូវបានដាក់ភ្ជាប់ទៅតាមភាពដែលអាចធ្វើបាន ហើយមូលដ្ឋានសំរាប់ជំរើសដែល បានជ្រើសរើសត្រូវបានបញ្ជាក់។

## ៥.១ ជំរើសសំរាប់ទីតាំងទំនប់

ក្នុងកំឡុងពេលនៃការរៀបចំរបាយការណ៍បុរេសិក្សាសមិទ្ធិលទ្ធភាព សំរាប់គំរោងវារីអគ្គីសនីសេសានក្រោមទី២ ជំរើសពីរសំរាប់ទីតាំងទំនប់ត្រូវបានផ្តោតការយកចិត្តទុកដាក់សំរាប់ការសិក្សា ដោយផ្អែកតាមការធ្វើអង្កេតនៅទីវាល និង ដោយប្រើប្រាស់ឯកសារឋានលេខា ដែលមានដូចតទៅ:

- **<u>ទីតាំងទី ១ (T1)</u>**

T1 មានទីតាំងប្រហែល ១,៥គម នៅខាងក្រោមខ្សែទឹកនៃទីតាំងប្រសព្វរវាងទន្លេសេសាន និង ទន្លេស្រែពក ជាកន្លែងដែលមានស្រទាប់ថ្ម (Bedrock) ស្ថិតនៅបាតទន្លេ។ អ័ក្សរបស់ទំនប់ត្រូវបានកំណត់តាមកូអរដោនេតាមពីរចំនុច A1, B1:

- ចំនុច A1 : X= ១៥០១៦៨៣,៨៩២១; Y = ៣២២១១០,១៨២១
- ចំនុច B1 : X = ១៤៩៨៤៦០,៨៧៦១; Y = ៣១០៧២៨,៦១៥៤

- **<u>ទីតាំងទី ២ (T2)</u>**

T2 មានទីតាំងប្រហែល ៦,៥ គម នៅខ្សែទឹកខាងក្រោមនៃទីតាំងទី១។ កូអរដោនេភូមិសាស្ត្រនៃចំនុចពីរនៅលើ អ័ក្សទំនប់ត្រូវបានកំណត់ដូចខាងក្រោម:

- ចំនុច A2: X= ១៤៩៨១១៥,៩៨៤៣; Y = ៣០៤៧១៧,៧០២៩
- ចំនុច B2: X = ១៥០៤៨៨៨,៦៧៦៥; Y = ៣០៥៦២៦,៤២៩៧

នៅទីតាំងទី ២ មានជំរើសពីរសំរាប់ទីតាំងអាគារផលិតថាមពលត្រូវបានគិតគូរសំរាប់គំរោង:

(i) ជំរើស ១: អាគារផលិតថាមពលមានទីតាំងនៅបាតទន្លេ (T2-1)

(ii) ជំរើស ២: អាគារផលិតថាមពលមានទីតាំងនៅលើច្រាំងខាងឆ្វេង (T2-2)

លក្ខណៈបាតទន្លេចាប់ពីទីតាំង T1 ដល់ T2 មានជំរាលទាប (ជំរាលមធ្យមនៃកំណាត់ទន្លេនេះគឺ 0,000៨)

Draft

Draft

រយៈកំពស់នៃដីដែលខុសគ្នាគឺប្រហែល ៥ ម។ បាតទន្លេនៅទីតាំង T1 និង ទីតាំង T2 គឺ ៤៧ ម និង ៤១ ម ។

ដោយសារការលេចចេញនូវរបាំងថ្ម ដូចនេះខ្សែកោងនៃផ្ទៃទឹករវាង T1 និង T2 មិនមានភាពខុសគ្នាច្រើនទេ (ប្រហែល ០,៩ ម នៅក្នុងខែ វិច្ឆិកា-ធ្នូ ២០០៧)។ ប៉ុន្តែ មានភាពខុសគ្នាខ្លាំងនៃខ្សែកោងផ្ទៃទឹកនៅ T2 និង ផ្នែកខាងក្រោមខ្សែទឹកនៃកន្លែងទឹកធ្លាក់នៅតំបន់ភូមិភ្លុក (ដែលជាកន្លែងបង្ហូរចេញនៃអាគារផលិតថាមពល ក្នុងជំរើស T2.2)។ ដោយផ្អែកលើលទ្ធផលវាស់វែងនៅខែធ្នូ ២០០៧ ភាពខុសគ្នានៃផ្ទៃទឹកគឺ ៣,១ ម។ ប្រសិនបើកន្លែងផ្លូវបង្ហូរទឹកចេញ ត្រូវបានរៀបចំនៅខាងក្រោមខ្សែទឹកនៃកន្លែងទឹកធ្លាក់ នោះទិន្នផលអគ្គិសនីពីអាគារផលិតថាមពលអាចកើនឡើងគួរអោយកត់សំគាល់ ដោយសារកំពស់ខុសគ្នានេះត្រូវបានទាញយកអត្ថប្រយោជន៍យ៉ាងពេញលេញ។



Draft

**រូបភាពទី ៣៦: ផែនទីទីកន្លែងនៃជំរើសទីតាំងទំនប់**

សំណង់បង្វែរទឹក : សំរាប់ជំរើសទីតាំងទំនប់ T2.2 កិច្ចការនៅនឹងផ្លូវទឹក ត្រូវបានរៀបចំនៅលើច្រាំង ត្រូវបានធ្វើដោយឡែកពីសំណង់មេ ហើយសំណង់នេះអាចធ្វើឡើងទាំងនៅក្នុងរដូវវស្សា និង រដូវប្រាំង។ វាជាផ្នែកមួយសំខាន់នៃកាលវិភាគសាងសង់របស់គំរោង ដូចនេះជំរើសទីតាំងទី២ មានសមត្ថភាពល្អប្រសើរត្រូវទៅតាមកាលវិភាគទូទៅរបស់គំរោង ច្រើនជាងជំរើស ទីតាំងទី១ និងជំរើស T2.1 ហើយតំលៃសំរាប់ការងារបង្វែរទឹកមានតំលៃទាប។ ទឹកត្រូវបានហូរពីលើទំនប់បង្ហៀរដែលមិនទាន់រួចរាល់ នៅរដូវទឹកជំនន់។ ពត៌មានលំអិតសូមមើលនៅក្នុងប្លង់រចនា ០១.០៧.TC.០៣ និង ០៤ នៃរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង។

សំរាប់ជំរើសទីតាំងទំនប់ T1 និង T2.1: ផ្លូវទឹកជាមួយគ្នានឹងទំនប់បង្ហៀរ ត្រូវបានរៀបចំនៅបាតពោះទន្លេ ដូចនេះសំណង់បង្វែរទឹកត្រូវធានាការសាងសង់ទាំងនៅក្នុងរដូវជំនន់ និងរដូវប្រាំង ។ ដូចនេះទំហំរបស់ជញ្ជាំង បេតុង

និងទំនប់បង្វៀងទឹកមានកំពស់ខ្ពស់ ដោយសារអាំងតង់ស៊ីតេនៃផ្ទៃកនិមួយៗដែលបានរៀបចំនៅក្នុងតំបន់ខ្ពស់ ដូចនេះវិធីសាស្ត្រនៃការរៀបចំសំណង់មានភាពលំបាក ។ លើសពីនេះទៀតលូបង្វែរទឹក (diversion culvert) មានទីតាំងនៅលើច្រាំងខាងស្តាំ ប៉ុន្តែឆ្នាំទីមួយនៃការងារសាងសង់មិនមានស្ថានបណ្តោះអាសន្នទេ ដូច្នេះកាលវិភាគសំណង់នឹងត្រូវខ្លីជាង ជំរើសទីតាំង T2.2 ហើយក៏រិតត្រូវតាមកាលវិភាគសំណង់របស់គំរោងទាំងងស់មានតិចតួចណាស់។ ជំរើសនៃសំណង់បង្វែរទឹកលំអិត សូមមើលនៅក្នុង ០១.០៧.TC.០១ និង ០២ នៃរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង។

## ៥.២ លក្ខណៈភូមិសាស្ត្រ និងឋានលេខានៃជំរើសទីតាំងទំនប់

សំរាប់ជំរើសទីតាំងទំនប់ គេបានប្រើប្រាស់ផែនទីមានមាត្រដ្ឋាន ១:២០០០ ក្នុងការរៀបចំរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព ដើម្បីវាយតំលៃលើគ្រប់តំបន់នៃជំរើសទីតាំងទំនប់ ដើម្បីកំណត់ទីតាំងអាង កំណត់ការខូចខាតលើដី/ព្រៃឈើ សួនដំណាំ និង ផ្ទះសំបែង។ ការកំណត់ផែនទី និង ការវាស់វែងក៏ត្រូវបានធ្វើផងដែរដោយប្រើប្រាស់ផែនទីថតពីលើអាកាស (Aerial photograph) ដែលមានមាត្រដ្ឋាន ១:១០ 000 ជាមួយនឹងខ្សែកុងទួរ ២ ម៉ែត្រ ដើម្បីធានាបានពីភាពច្បាស់លាស់សំរាប់ការរៀបចំបួង់ និង ការវាយតំលៃពីជំរើសទីតាំងទំនប់។

នៅតាមបណ្តោយអ័ក្សនៃជំរើសទីតាំងទាំងពីរសំរាប់ទំនប់ គេបានធ្វើការខួងរណ្តៅដើម្បីបញ្ជាក់ពីលក្ខណៈវិស្វកម្ម និង ភូគព្ភសាស្ត្ររបស់ទីតាំងជំរើសនិមួយៗ ។ ការអង្កេតមើលពីឋានលេខា និង ភូគព្ភសាស្ត្រ ត្រូវបានធ្វើការពិចារណាក្នុងការជ្រើសរើស នូវជំរើសទីតាំងទំនប់ដែលជាទីគាប់ចិត្ត ។ លទ្ធផលពីការអង្កេតមានបង្ហាញដូចខាងក្រោម:

- បាតទន្លេនៃទីតាំង T1 និង ទីតាំង T2 មានកំពស់ ៤៧ម និង ៤១ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ) ។
- ទីតាំងជំរើសទំនប់មានទំហំបាតទន្លេធំទូលាយ ហើយតាមច្រាំងទន្លេមានដីដែលមានចំណោតទាប ភាគច្រើនមានផ្ទៃរាប។ ហេតុដូចនេះទំនប់ដែលបានស្នើឡើងមានប្រវែង ៦,៥-៨ គម។
- លក្ខណៈភូគព្ភសាស្ត្រនៅទីតាំង T1: វាមានទីតាំងនៅលើតំបន់ដែលមានសិលាបន្ទុះភ្នំភ្លើង andezite សិលាគ្រឹះ ជាសិលាដែលកើតនៅអាយុកាល Devonian-Carbonian ដែលគ្របដណ្តប់ដោយកំទេចកំណ N2-Q1 និង កំទេចកំណបច្ចុប្បន្ន Quaternary នៃអាយុកាល Holoxen។ លក្ខណៈភូគព្ភសាស្ត្រវិស្វកម្មមានភាពគាប់ប្រសើរដោយជាសិលា andezite (ដែលលេចឡើងនៅបាតទន្លេ) មានស្ថេរភាពខ្ពស់សំរាប់ទ្រទ្រង់គ្រឹះទំនប់បេតុង ។ ជើងទំរជាច្រើន ដែលមានស្រទាប់ផ្ទុកទំងន់ដូចគ្នាៗ ដាក់នៅកន្លែងត្រឹមត្រូវនៃខឿនទំនប់ ។
- លក្ខណៈភូគព្ភសាស្ត្រនៅទីតាំងទំនប់ T2: បាតទន្លេនៅទីតាំង T2 មានភូគព្ភសាស្ត្រស្មុគស្មាញ។ បាតទន្លេទាំងមូលគ្របដណ្តប់ដោយដីខ្សាច់ ស្រទាប់ថ្មតាមច្រាំងខ្សាច់លេចនៅផ្ទៃខាងលើជាកំទេចកំណបែបខ្សាច់ លាយ



Draft

ជាមួយគ្រួសនៃតំបន់ IIA ។ សល់ពីនេះ នៅមានស្រទាប់ aQ កំរាស់ប្រហែល ២-៤ម៉ែត្រ. ស្រទាប់ស្តើង IA1, IA2 < ១ ម៉ែត្រ ហើយតំបន់ IIA ជាថ្មរឹង។ រចនាសម្ព័ន្ធភូគព្ភសាស្ត្រក៏មានលក្ខណៈខុសគ្នាខ្លាំងដែររវាងច្រាំងខាងឆ្វេង និង ច្រាំងខាងស្តាំ ។ នៅច្រាំងខាងស្តាំ គឺជាប្លុកថ្ម andezite ដែលមានកំទេចកំណមិនស្ថិតស្ថេរ N2-Q1 គ្របពីលើវា។ នៅច្រាំងខាងឆ្វេង មានកំទេចកំណមិនស្ថិតស្ថេរ Quaterary ដែលគ្របពីលើស្រទាប់ថ្ម J1-2 ។ នៅបាតទន្លេ មានស្រទាប់ភក់ល្បាប់កំរាស់ ២.៥ ម៉ែត្រ គ្របពីលើថ្មក្តាំងនៃស្រទាប់ J1-2។ ដូច្នេះសំរាប់ទំនប់បង្ហៀរ និង ទំនប់បេតុង ដែលមានទីតាំងនៅបាតទន្លេ តំរូវអោយមានដាក់បាយអជាប់មាំដើម្បីការពារគ្រឹះរបស់វា។ កន្លែងការដ្ឋានយកដីស្ថិតនៅជិតទីតាំងសាងសង់នេះ ហើយកន្លែងយកថ្ម និង ខ្សាច់អាចយកចេញពីតំបន់របស់ទីតាំង T1 ។

- ទីតាំង T2 ស្ថិតនៅប្រហែល ៦.៥ គម ខាងក្រោមទីតាំង T1. ដូច្នេះផ្ទៃដីលិចលង់នៃទីតាំង T2 មានទំហំធំជាងជំរើសមុន ហើយចំនួននៃគ្រួសាររងផលប៉ះពាល់មានចំនួនច្រើនផងដែរ ។ ចំណែកថាមពលផលិតបានក៏នឹងមានបរិមាណច្រើនជាងមុនដែរ ដោយសារមាឌស្តុកទឹកក្នុងអាងមានទំហំធំ។
- ផ្លូវបំរើអោយការសាងសង់ និង ការប្រតិបត្តិសំរាប់ជំរើសទីតាំងទាំងពីរ គឺផ្លូវជាតិលេខ៧៨ ហើយប្រវែងផ្លូវទៅទៅការដ្ឋាន សាងសង់ និង ការប្រតិបត្តិសំរាប់ជំរើសទីតាំងទាំងពីរមានប្រហាក់ប្រហែលគ្នា។

- **<u>បរិមាណការងារសំខាន់សំរាប់ជំរើសទីតាំងទំនប់</u>**

ដោយផ្អែកលើគ្រោងប្លង់របស់គំរោងដែលបានស្នើឡើងរបស់ជំរើសជំរើសទីតាំងទាំងពីរ បរិមាណ និងតំលៃសាងសង់របស់ជំរើសទីតាំងនិមួយ ត្រូវបានគណនាដែលមានបង្ហាញក្នុងតារាងដូចខាងក្រោម:

**តារាងទី ៤៧:** បរិមាណនៃជំរើសទីតាំងទំនប់

| ការងារ | ខ្នាត | ជំរើស T1 | ជំរើស T2 | |
|---|---|---|---|---|
| | | | ជំរើស T2.1 | ជំរើស T2.2 |
| ការជីកដី | ម៣ | ១.៧៨២.៣៨៦ | ២.០៩៦.៨២០ | ១៤.២៤៩.២៥០ |
| ទំនប់លើកពីដី | ម៣ | ៨.៤៤៣.៨៥៤ | ៩.៦៦៣.០៤០ | ៩.៦២៩.០៧០ |
| បរិមាណបេតុង | ម៣ | ៦២៤.៨៨២ | ៦៨៣.៥០៤ | ៦៤៥.៦៩៦ |
| ឧបករណ៍ Hydro-mechanical | តោន | ៨.៧២០ | ៨.៧៨១ | ៨.៨០៨ |
| ឧបករណ៍ Hydraulic-mechanical | មេហ្គាវ៉ាត់ | ៤០០ | ៤២០ | ៤៨០ |

Draft

សំរាប់ជំរើសទីតាំងទំនប់និមួយៗ. ជំរើសបង្វែរត្រូវបានធ្វើការពិចារណាដូចមានបង្ហាញនៅក្នុងតារាងទី ៤៨ ។ ជំរើសនិមួយៗត្រូវបានគិតគូរពិចារណា ដើម្បីអោយសំរេចបានតាមគោលដៅនៃការសាងសង់ ។

**តារាងទី ៤៨:** ទំហំនៃសំណង់បង្វែរទឹក

| ការងារ | ខ្នាត | ជំរើស T1 | | ជំរើស T2 | |
|---|---|---|---|---|---|
| | | ប្រឡាយបង្វែរនៅរដូវជំនន់ | លូបង្វែរនៅរដូវជំនន់ | ជំរើស T2.1 | ជំរើស T2.2 |
| ការជីកដី | $ម^៣$ | ៥.០០០.០០០ | ២៤.៩២៥ | ១០៩.៨៣០ | ១.៨៧៦.៥៤១ |
| ទំនប់លើកពីដី | $ម^៣$ | ២៦៣.១០០ | ១.៤៦៧.០០០ | ៦៣២.៤៩៩ | ២៦៣.១០០ |
| បរិមាណបេតុង | $ម^៣$ | 0 | ៣៩.៣០៧ | ៦៣.៣៧១ | 0 |

## ៥.៣ ជំរើសកំរិតកំពស់ទឹកក្នុងអាងស្តុក (ផ្គត់ផ្គង់ពេញលេញ)

គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ អាចរៀបចំជាមួយនឹងនីវ៉ូផ្គត់ផ្គត់ពេញលេញបីកំរិតនៅក្នុងអាងដែលបានស្នើឡើងដូចខាងក្រោម:

- នីវ៉ូផ្គត់ផ្គង់ពេញលេញ (FSL) នៅកំរិតកំពស់ ៨០ម
- នីវ៉ូផ្គត់ផ្គង់ពេញលេញ (FSL) នៅកំរិតកំពស់ ៧៥ម
- នីវ៉ូផ្គត់ផ្គង់ពេញលេញ (FSL) នៅកំរិតកំពស់ ៧០ម

ជាមួយនឹង FSL ៨០ម ទំហំផ្ទៃដីលិចទឹកសរុបនៅក្នុងផ្ទៃអាងមានប្រហែល ៨១៣.២ $គម^២$ ដោយរាប់បញ្ចូលទាំងផ្ទៃទឹកដែលមានស្រាប់ផង ។ ដីកសិកម្ម និងផ្ទៃដីលំនៅដ្ឋានដែលមានស្រាប់នៅក្នុងឃុំចំនួនបីរួមមាន ស្រែគរ តាឡាត់ និងក្បាលរមាសនៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែងនឹងត្រូវបានលិចលង់ទាំងស្រុង ដោយអាងស្តុកនេះ ហើយឃុំភ្លុក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និង ឃុំស្រែអង្គ្រងក្នុងស្រុកកូនមុំក្នុងខេត្តរតនគិរី នឹងត្រូវលិចលង់មួយផ្នែកនៅក្នុងអាងនេះផងដែរ ។ ការតាំងទីលំនៅសារជាថ្មីដ៏ធំមួយ នឹងត្រូវធ្វើឡើង ។ វានឹងមានហេតុប៉ះពាល់យ៉ាងខ្លាំងមួយទៅលើសង្គម និងបរិស្ថាន ។ ដូចនេះ FSL ៨០ម៉ែត្រ ត្រូវបានពិចារណាថា ពុំមានសមិទ្ធិលភាពទេ សំរាប់រោងចក្រវារី អគ្គិសនីសេសានក្រោមទី២នេះ ។

ជាមួយនឹង FSL ៧៥ ម៉ែត្រ ទំហំផ្ទៃដីលិចទឹកសរុបនៅក្នុងផ្ទៃអាងមានប្រហែល ៣៣៥.៦$គម^២$ រាប់បញ្ចូលទាំងផ្ទៃទឹកដែលមានស្រាប់ផង។ ផ្នែកខ្លះនៃដីកសិកម្ម និងតំបន់លំនៅដ្ឋាននៃឃុំបី (ឃុំស្រែគរ តាឡាត់ និងក្បាលរមាស) ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង នឹងត្រូវគ្របដណ្តប់ដោយអាងមួយភាគធំ ប៉ុន្តែមិនមានលិចលង់ដល់ឃុំនៅខេត្តរតនគិរីដូច FSL ៨០ម៉ែត្រទេ ។




# រូបភាពទី ៣៧: ជំរើសទីរួំផ្គត់ផ្គង់ពេញលេញ

ការផ្លាស់ប្តូរទីលំនៅ និងការតាំងលំនៅសារជាថ្មី ចំពោះគ្រួសារ មួយចំនួនដែលរស់នៅតំបន់ទាបៗក្នុងឃុំខាងលើនឹងកើតមានឡើង ។ ជាមួយនឹង FSL ៧៥ ម៉ែត្រ នឹងមានហេតុ ប៉ះពាល់ខ្ពស់ដល់សង្គម និងបរិស្ថាន នៅតែត្រូវបានប៉ាន់ប្រមាណ ហើយពីភាពដែលអាចធ្វើទៅបានពីជំរើសនេះនៅ ត្រូវបានយកមកពិចារណាលំអិតគ្រប់លក្ខខណ្ឌទាំងអស់សំរាប់ការអភិវឌ្ឍន៏គំរោង ។

ជាមួយនឹង FSL ៧០ម ទំហំផ្ទៃដីលិចទឹកសរុបនៅក្នុងផ្ទៃអាងមានប្រហែល ១២៩.១គម $^{២}$ រួមបញ្ចូលទាំងផ្ទៃទឹកដែលមានស្រាប់ផង។ ដីកសិកម្ម និងតំបន់លំនៅដ្ឋានដែលមាននៅក្នុងឃុំបី ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែងនឹងត្រូវលិចលង់ក្នុងអាងមានបរិមាណតិចតួច (ដីកសិកម្មត្រឹមតែ ៦០ ហត ប៉ុណ្ណោះ)។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរទីលំនៅ និងការតាំងទីលំនៅសារជាថ្មីសំរាប់គ្រួសារខ្លះពីផ្ទៃដីទាបទៅកាន់ដីខ្ពស់ នៅក្នុងឃុំទាំងបីនៅតែកើតឡើង ជាពិសេសនៅឃុំស្រែគរ និងក្បាលរមាស។ គេអាចទស្សន៏ទាយបានថា ហេតុប៉ះពាល់អាចកើតមានពីតិចតួចទៅមធ្យម ទៅលើធនធានសង្គម និង បរិស្ថាន។

**តារាងទី ៤៩:** ផ្ទៃដីលិចលង់ ជាមួយនឹង FSL ខុសៗគ្នានៅក្នុងអាង

| ប្រភេទដីប្រើប្រាស់ | បរិវេណជំនន់ (ហត) | | |
|---|---|---|---|
| | FSL ៧០ម | FSL ៧៥ម | FSL ៨០ម |
| ដីព្រៃ | ១០.៥៤៨,១៣០ | ២៨.៩៦៩,៤៩៥ | ៦៩.១២៦,៦៨ |
| ផ្ទៃទឹកដែលមានស្រាប់ | ១.៩០៦,៨១១ | ២.៩៨៩,៦៥៣ | ៤.៥៧២,២៦៣ |
| ដីព្រៃរបោះ | ៣៧៣,១៧៨ | ១.២៩០,៥៥៨ | ៣.៣៨១,២១៤ |
| ដីកសិកម្ម | ៤៧,៩២២ | ២១៨,៧១៤ | ៣.១៣៦,១៩២ |
| ដីវាលស្មៅ | ៣០,៦១៧ | ៤៨,១០៩ | ៩៩៩,៩០០ |
| ដី និង ថ្ម | ៣,៣៧៦ | ៤៧,៣៩២ | ១០៤,៦៤៥ |
| សរុប: | ១២.៩១០,០៣៤ | ៣៣.៥៦៣,៩២១ | ៨១.៣២០,៨៩៤ |

**តារាងទី ៥០:** ផ្ទៃដីលិចលង់នៃ ព្រៃ និង ដីសម្បទាន

| ឈ្មោះក្រុមហ៊ុន | បរិវេណលចទឹក (ហត) | | |
|---|---|---|---|
| | FSL ៧០ម | FSL ៧៥ម | FSL ៨០ម |
| ក្រុមហ៊ុន ប្រេ្កនលែនដ៏ | ១.៩១៤,៥៧១ | ៣.៩៤០,២៣៥ | ១៤.៤១៩,២៧១ |
| ក្រុមហ៊ុន ភាភីមិច | ១.២៩៣,៨០៦ | ២.៩១១,៩១៧ | ៤.២៦៤,៣៦២ |
| ក្រុមហ៊ុន ភូម៉ាឌី អិនវេសមេន គ្រុប | ៥៥៤,៦៧៥ | ១.៤៧៩,៥៥៧ | ៤.០៧៥,៥៩១ |
| ក្រុមហ៊ុន កសិ-ឧស្សាហកម្ម ស៊ីវ ហ្គិច | ៤៦៦,០៤៦ | ១.៤៦៧,៥២២ | ៣.៥៥២,០១៧ |

Draft

| | | | |
|---|---|---|---|
| ក្រុមហ៊ុន វិនិយោគកសិ-ឧស្សាហកម្មសុភក្រនីកា | ១៨៣.៩០៩ | ៥១៦.៤៧៤ | ១.០៣៩.៣៩០ |
| ក្រុមហ៊ុន សល សុភា ពាណិជ្ជកម្ម | ១.៣១៨ | ៨៤.០៥៣ | ៤៧១.៩២៧ |
| **សរុប** | **៤.៤១៤.៣២៥** | **១០.៣៩៩.៧៥៨** | **២៧.៨២២.៥៥៨** |

នៅក្នុងតារាងទី ៥០ បានបង្ហាញយ៉ាងច្បាស់ថា ផ្ទៃដីលិចលង់នៅលើដី និង ព្រៃសម្បទានជាមួយនឹង FSL ៧០ម មានទំហំតូចជាងពីរដងនៃផ្ទៃដីលិចលង់ដោយ FSL ៧៥ ម ។ តែទោះជាយ៉ាងណាក៏ដោយផ្ទៃដី និងព្រៃសម្បទានទាំងអស់ខាងលើនឹងត្រូវលិចលង់តូច ឬធំ អាស្រ័យតាមកំពស់ទឹក FSL ទាប ឬ ខ្ពស់ ។ ហេតុនេះ ទំនាស់ដីធ្លីនឹងកើតមាន រវាងគំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ ជាមួយនឹងម្ចាស់ ដី និង ព្រៃសម្បទាន ។

ប៉ុន្តែការតាំងទីលំនៅសារជាថ្មីរបស់សហគមន៍នៅក្នុងតំបន់គំរោង គឺជាកត្តាចំបងនៃហេតុប៉ះពាល់សង្គម ដែលត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំគំរោង និងការរចនាប្លង់ ។ តារាងទី ៥១ បង្ហាញយ៉ាងច្បាស់ពីឈ្មោះឃុំ និង ចំនួនគ្រួសារសរុបដែលនឹង ត្រូវផ្លាស់ប្តូរទីលំនៅ ឬ តាំងទីលំនៅឡើងវិញ នៅតំបន់តាំងទីលំនៅសារជាថ្មី អាស្រ័យទៅតាមកំរិតកំពស់ FSL របស់អាង ។

**តារាងទី ៥១:** គ្រួសារ និង ប្រជាជនដែលរងផលប៉ះពាល់ដោយសារគំរោង

| លរ | ឈ្មោះឃុំ | ប្រជាជនសរុប | | ផលប៉ះពាល់ដោយសារគំរោងជាមួយនឹងកំរិតទឹកផ្សេងៗគ្នា | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | FSL ៧០ម | | | FSL ៧៥ម | | | FSL ៨០ម | | |
| | | គ្រួសារ | ប្រជាជន | PAH | APs | % | PAH | APs | % | PAH | APs | % |
| ១ | ក្បាលរមាស | ៤៧០ | ២១៩១ | ១៥៧ | ៧៦៨ | ៣៣ | ៤៥៣ | ២១០៩ | ៩៦ | ៤៧០ | ២១៩១ | ១០០ |
| ២ | តាឡាត់ | ៦៤៨ | ២៨៩២ | ០ | ០ | ០ | ២៦៧ | ១២២៩ | ៤១ | ? | ? | ៩០? |
| ៣ | ស្រែគរ | ៣៣២ | ១៤១៨ | ៣៣២ | ១៤១៨ | ១០០ | ៣៣២ | ១៤១៨ | ១០០ | ៣៣២ | ១៤១៨ | ១០០ |
| ៤ | ភ្លុក | | | | | | | | | | | |
| | ទីតាំងទំនប់ទី១ | ១៨៨ | ៨២៤ | ៧ | ២៩ | ៤ | ៧ | ២៩ | ៤ | | | |
| | ទីតាំងទំនប់ទី២ | ១៨៨ | ៨២៤ | ១៤ | ៥៣ | ៧ | ១៤ | ៥៣ | ៧ | | | |
| ៥ | ស្រែអង្រ្កង | ៣១៦ | ១៦១០ | ០ | ០ | ០ | ០ | ០ | ០ | ? | ? | ២០? |

ប្រភព: ទិន្នន័យទទួលបានពីក្រុមសិក្សាការតាំងទីលំនៅសារជាថ្មី, PECC-១, ខែឧសភា ២០០៨។

អាស្រ័យទៅតាមទិដ្ឋភាពនៃហេតុប៉ះពាល់ទៅលើសង្គម និង បរិស្ថាន ជាមួយកំពស់ FSL ៧០ម និង ៧៥ម គេអាចធ្វើការពិចារណាគិតគូរ សំរាប់ការអភិវឌ្ឍន៍គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២បាន ។ ផ្អែកទៅតាមលទ្ធផលបច្ចេកទេស និងសេដ្ឋកិច្ច នៅក្នុងការសិក្សាពីសមិទ្ធិលទ្ធភាព ឃើញថា កំពស់ FSL ៧៥ម ត្រូវបានជ្រើសរើសយកសំរាប់រោងចក្រវារីអគ្គិសនី សេសានក្រោមទី ២។



Draft

តារាងខាងក្រោមពណ៌នាអំពីការវិភាគពីផលប៉ះពាល់ជាចម្បងជាមួយជំរើសទំនប់ទីតាំងទី១ និងទី២ ជាមួយនឹងការផ្គត់ផ្គង់ទឹកកំរិតពេញលេញ FSL ៧៥ម ។

**តារាងទី ៥២:** ការពណ៌នាពីការវិភាគផលប៉ះពាល់ចម្បងនៃទីតាំងទី ១ និង ទី ២

| ជំរើសទីតាំងទំនប់ | លក្ខណៈ ប៉ានលេខា | លក្ខណៈភូគព្ភសាស្ត្រ | ផ្ទៃដីលិចទឹក ជាមួយ FSL ៧៥ម | ប្រវែង ទំនប់មេ សរុប |
|---|---|---|---|---|
| <u>ទីតាំងទី ១:</u> ១.៥ គម ពី ចំនុចប្រសព្វនៃទន្លេសេសាន និង ទន្លេស្រែពក | កំពស់បាតទន្លេ, ៤៧ម | ថ្ម andezite មានលក្ខណៈជាប់ប្រសើរ | ៣៣៥.៦ គម² | ៨០០០ ម |
| <u>ទីតាំងទី ២:</u> ប្រហែល ៦.៥ គម ខាងក្រោម ទីតាំងទី ១ | កំពស់បាតទន្លេ, ៤១ម | ភូគព្ភសាស្ត្រស្មុគស្មាញ, មានថ្មអាដ្យាស៊ីតមិនជាប់ល្អ, ស្រទាប់ថ្មលាយជាមួយខ្សាច់នៅតាមច្រាំងទន្លេ, ខ្សាច់កំទេចកំណរលាយជាមួយគ្រួសនៃតំបន់ IIA, សំណល់ស្រទាប់ aQ កំរាស់ប្រហែល ២-៤ម៉ែត្រ | ៣៨២.៧ គម² | ៦៨៣៣ ម |

**តារាងទី៥៣:** តំលៃនៃជំរើសទីតាំងទំនប់

| ប៉ារ៉ាម៉ែត្រ | ខ្នាត | ជំរើស T1 | ជំរើស T2 | |
|---|---|---|---|---|
| | | | ជំរើស T2.1 | ជំរើស T2.2 |
| ទុនវិនិយោគសរុប | លានដុល្លា អាមេរិក | ៥០៥.៩៥ | ៥២៣.៦៥ | ៦១៨.១៨ |

យោងទៅតាមលទ្ធផលបច្ចេកទេស បរិស្ថាន និង សេដ្ឋកិច្ច ឃើញថាជំរើសសមស្របសំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ គឺទីតាំងទីមួយ T1 (១.៥ គម ពីក្រោមចំនុចប្រសព្វនៃ ទន្លេសេសាន និងទន្លេស្រែពក) និងកំពស់ទឹក FSL ៧៥ម នៅក្នុងអាង ។



Draft